ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧.០៧-១៣២ ប្រ.ក

លិខិតចូល

ថ្ងៃទី១៧ ខែ[illegible] ឆ្នាំ200៧

# ប្រកាស
## ស្តីពី
## ការគណនាមូលនិធិផ្ទាល់សុទ្ធរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

## ទេសាភិបាល ធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៤៤ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៤ ស្តីពីការតែងតាំង **ឯកឧត្តម ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា មានឋានៈស្មើទេសរដ្ឋមន្ត្រី
- យោងតាមស្មារតីនៃអង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០៧

## ស ម្រេ ច

**ប្រការ ១.-**

មូលនិធិផ្ទាល់សុទ្ធរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុត្រូវបានគណនាដូចតទៅ ៖

I- **សរុប A : ខ្ទង់ត្រូវបូក**

- ដើមទុន ឬទាយជ្ជទានដើមទុន
- ទុនបំរុងក្រៅពីទុនបំរុងពីការវាយតំលៃឡើងវិញ
- បុព្វលាភទាក់ទងនឹងដើមទុន (បុព្វលាភភាគហ៊ុន)
- សំវិធានធនចំពោះហានិភ័យទូទៅនៃប្រតិបត្តិការដោយមានការយល់ព្រមជាមុនពីធនាគារជាតិនៃកម្ពុជា

- ចំណេញរក្សាទុកសំរាប់វិនិយោគបន្ត (retained earnings)
- ចំណេញសុទ្ធ ដែលបានផ្ទៀងផ្ទាត់ហើយសំរាប់ឆ្នាំហិរញ្ញវត្ថុចុងក្រោយ [១]
- ខ្ទង់ផ្សេងៗទៀត ដែលអនុញ្ញាតដោយធនាគារជាតិនៃកម្ពុជា [២] ។

## II- សរុប B : ខ្ទង់ត្រូវដក

- ចំពោះភាគទុនិក: នាយក នាយកចាត់ការ និងសម្ព័ន្ធញាតិ
  - ចំណែកដើមទុនដែលមិនទាន់បានបង់
  - បុរេប្រទាន ឥណទាន មូលប័ត្រ និងកិច្ចសន្យារបស់ជនពាក់ព័ន្ធខាងលើ
- ការកាន់កាប់ភាគហ៊ុនផ្ទាល់តាមតំលៃចុះបញ្ជី
- ការខាតបង្គរ
- ចំណាយក្នុងការផ្តើមបង្កើត
- ការខាតដែលកំណត់តាមគ្រាក្រៅពីការខាតនាចុងការិយបរិច្ឆេទគណនេយ្យប្រចាំឆ្នាំ (រួមបញ្ចូលទាំងសំវិធានធនសំរាប់បំណុលនិងមូលប័ត្រសង្ស័យ) ។

## III- សរុប C : មូលនិធិផ្ទាល់សុទ្ធមូលដ្ឋាន = A - B

## IV- សរុប D : ខ្ទង់ត្រូវបូក

- ទុនបំរុងពីការវាយតំលៃឡើងវិញ ដោយមានការយល់ព្រមជាមុនពីធនាគារជាតិនៃកម្ពុជា
- អនុបំណុល (Subordinated debt) ដោយមានការយល់ព្រមជាមុនពីធនាគារជាតិនៃកម្ពុជាអាចបូកបញ្ចូល ១០០% នៃចំនួនមូលនិធិផ្ទាល់សុទ្ធមូលដ្ឋាន

---

[១] ក្រោយពីដកភាគលាភដែលត្រូវបែងចែក

[២] ឧទាហរណ៍ប្រាក់ចំណេញដែលបានកត់ត្រាតាមគ្រាក្រៅពីប្រាក់ចំណេញនៅចុងការិយបរិច្ឆេទគណនេយ្យប្រចាំឆ្នាំក្នុងលក្ខខ័ណ្ឌដែល ÷

- ប្រាក់ចំណេញនោះត្រូវបានកំណត់ក្រោយពេលបានចុះបញ្ជីនូវចំណាយទាំងអស់ណាដែលទាក់ទងនឹងគ្រានោះ និងចំណាយរំលស់ព្រមទាំងសំវិធានធន និងតំលៃគណនីកែតំរូវ
- ប្រាក់ចំណេញនោះត្រូវបានដកចេញ ពន្ធនិងភាគលាភសុទ្ធដែលនឹងត្រូវបង់ ហើយត្រូវបានផ្ទៀងផ្ទាត់ដោយសវនការគណនី

- ខ្ទង់ផ្សេងៗទៀត ដោយមានការយល់ព្រមជាមុនពីធនាគារជាតិនៃកម្ពុជាអាចបូកបញ្ចូលក្នុងការគណនាមូលនិធិផ្ទាល់សុទ្ធមិនឱ្យលើសពីចំនួននៃមូលនិធិផ្ទាល់សុទ្ធមូលដ្ឋាន[៣] ។

V- **សរុប** E **: ខ្ទង់ត្រូវដក**

- ភាគកម្មមូលនិធិផ្ទាល់ក្នុងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនានា
- ខ្ទង់ផ្សេងៗ[៤] ។

VI- **សរុប** F **: សរុបមូលនិធិផ្ទាល់សុទ្ធ** = C + D - E

**ប្រការ ២.-**

មូលនិធិផ្ទាល់សុទ្ធដែលបានគណនាមកនេះ ត្រូវបានយកមកគិតគូរសំរាប់ការគណនាអនុបាតប្រុងប្រយ័ត្ននិងអនុបាតផ្សេងទៀត ។

**ប្រការ ៣.-**

គ្រឹះស្ថានដែលមិនគោរពតាមខ្លឹមសារនៃប្រកាសនេះ នឹងត្រូវរងទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងមាត្រា ៥២ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។

**ប្រការ ៤.-**

រាល់លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

---

[៣] ខ្ទង់ផ្សេងៗអាចរួមមានខ្ទង់ទាំងឡាយដូចខាងក្រោមនេះ ÷

- មូលនិធិដែលបានធានាទៅវិញទៅមកយ៉ាងពេញលេញ
- មូលនិធិសាធារណៈដែលបែងចែកសំរាប់ធានាប្រភេទប្រតិបត្តិការឥណទាន
- ឧបត្ថម្ភធនសាធារណៈ ឬឯកជនដែលមិនត្រូវសងវិញ
- ដើមទុនជាជំនួយ

[៤] ឧទាហរណ៍ : ចំណាយដែលត្រូវបែងចែកសំរាប់ច្រើនការិយបរិច្ឆេទ

**ប្រការ ៥.-**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៦.-**

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ សីហា ឆ្នាំ២០០៧

ទេសាភិបាល

ជា_ចាន់តូ

**កន្លែងទទួល**

- ដូចប្រការ ៥ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ

**ចម្លងជូន**

- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាបជាព័តមាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"

KINGDOM OF CAMBODIA
NATION RELIGION KING

NATIONAL BANK OF CAMBODIA

Number B7.07 – 132 Prokor

Unofficial Translation

# PRAKAS
# on
# The calculation of Microfinance Institutions' Net Worth

**The Governor of the National Bank of Cambodia**

- With reference to the Constitution of the Kingdom of Cambodia;
- With reference to the Royal Kram NS/RKM/0196/27, dated January 26, 1996, promulgating the Law on the Organization and Conduct of the National Bank of Cambodia;
- With reference to the Royal Kram NS/RKM/1199/13 of November 18, 1999, promulgating the Law on Banking and Financial Institutions;
- With reference to the Roya Decree NS/RKT/0904/244 of September 7, 2004, on the appointment of His Excellency **Chea Chanto** as Governor General of the National Bank of Cambodia, equivalent to Senior Minister;
- Pursuant to the recommendation made by National Bank of Cambodia management during the August 15, 2007, meeting.

## DECIDES

### Article 1

Microfinance Institutions' net worth shall be calculated as follows:

I- Sub-total A : Items to be added

- capital or endowment
- reserve, other than revaluation reserves
- premium related to capital (share premiums)
- provision for general banking risks, with the prior agreement of the National Bank of Cambodia
- retained earnings

- audited net profit for the last financial year [1]
- other items approved by the National Bank of Cambodia [2]

II- Sub-total B : Items to be deducted

- for shareholders, directors, managers and their next of kin
  - unpaid portion of capital
  - advances, loans, security and the agreement of the persons concerned as defined above
- holding of own shares at their book value
- accumulated losses
- formation expenses
- losses determined on dates other than the end of the annual accounting period (including provisions to be made for doubtful debt and securities)

III- Total C : BASE NET WORTH = A - B

IV- Sub-total D : Items to be added

- revaluation reserves, with the prior agreement of the National Bank of Cambodia
- subordinated debt, with the prior agreement of the National Bank of Cambodia, up to 100% of base net worth
- other items, with the prior agreement of the National Bank of Cambodia, could be included in the calculation of net worth and shall not be more than base net worth [3]

V- Sub-total E : Items to be deducted

- equity participation in banking and financial institutions
- other items [4]

VI- Total F : TOTAL NET WORTH = C + D - E

---

[1] After deduction of dividend to be distributed.

[2] For example, profit as recorded on dates other than the end of the annual accounting period.
Provided that:
- they are determined after posting to the accounts all the charges relating to the period and allowances to the depreciation, provision and value adjustment accounts;
- they are calculated net of foreseeable taxes and dividend and have been verified by the auditors.

[3] The following may in particular appear among these items :
- fully mutualized guarantee funds;
- public funds allocated for guaranteeing types of credit operations;
- nonrepayable public or private subsidies;
- donated capital.

[4] Deferred charges, for example.

**Article 2**

The net worth as calculated above shall be taken into account in calculating prudential ratios and other ratios.

**Article 3**

Banks and Financial Institutions that are not compliant with this Prakas will be penalized according to Article 52 of the Law on Banking and Financial Institutions.

**Article 4**

All provisions contrary to those of this Prakas are hereby repealed.

**Article 5**

The General Director, the General Secretariat, the General Inspection, the General Cashier, all Departments of the National Bank of Cambodia, and all Banks and Financial Institutions under the National Bank of Cambodia's supervisory authority shall strictly implement this Prakas.

**Article 6**

This Prakas shall take effect from this signing date.

Phnom Penh, August 27, 2007

**The Governor**

**Signed and Sealed**

cc:
- All members of the Board of Directors
- The parties concerned as stated in Article 5
- File
- CM "for info"
- Administration Department of CM "for publication in the National Gazette"